Article
April 2022

# បច្ចេកវិទ្យា និងការលើកកម្ពស់បរិយាបន្នសង្គមនៅកម្ពុជា

ក្រុមជនងាយរងគ្រោះមួយចំនួន ដូចជា ជនពិការ ស្ត្រី កុមារ មនុស្សចាស់ និងជនជាតិភាគតិចជាដើម នៅតែជួបប្រទះនូវឧបសគ្គនានាដែលរារាំងពួកគាត់ក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចសង្គមបានពេញលេញដូចជនដទៃ បើទោះបីជាបណ្តាប្រទេសដែលពួកគេរស់នៅមានការរីកចម្រើនលើផ្នែកសេដ្ឋកិច្ច និងសង្គមក៏ដោយ។ ការលើកកម្ពស់ការចូលរួមរបស់ក្រុមជនងាយរងគ្រោះក្នុងសកម្មភាពនានាក្នុងសង្គមពិតជាមានសារៈសំខាន់ណាស់ ព្រោះថាវាមិនត្រឹមតែអាចជួយលើកកម្ពស់គុណភាពជីវិតរបស់ពួកគាត់ប៉ុណ្ណោះទេ តែថែមទាំងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់សង្គមទាំងមូល ដូចជា បង្កើននវានុវត្តន៍, បង្កើនផលិតភាពការងារ និងបង្កើនធនធានមនុស្ស ដែលមានប្រយោជន៍ដល់ការអភិវឌ្ឍប្រទេស និងពន្លឿនកំណើនសេដ្ឋកិច្ចជាតិ។

យោងតាមគេហទំព័រ Sacred Heart Mission «**បរិយាបន្នសង្គម**» សំដៅដល់ការរួមបញ្ចូលគ្រប់ក្រុមមនុស្ស ដោយមិនប្រកាន់ពី ភេទ អាយុ ពណ៌សម្បុរ កម្រិតសិក្សា មុខរបរ សាសនា កាយសម្បទា និងសញ្ជាតិ ទៅក្នុងគ្រប់សកម្មភាពសេដ្ឋកិច្ច សង្គម ហើយពួកគេមានសិទ្ធិស្មើៗគ្នាក្នុងការទទួលបាននូវឱកាស ដូចជា៖

- ទទួលបានការអប់រំ និងការបណ្តុះបណ្តាល
- មានការងារសមរម្យ
- មានការរក្សាសុខសុវត្ថិភាព
- ទទួលបាននូវសេវាសាធារណៈ ដូចជា សេវាសុខាភិបាល សេវាសង្គ្រោះបន្ទាន់ និងមធ្យោបាយធ្វើដំណើរសាធារណៈ
- អាចភ្ជាប់ទំនាក់ទំនងជាមួយក្រុមគ្រួសារ មិត្តភក្តិ និងមនុស្សក្នុងសហគមន៍
- និងអាចចូលរួមនៅក្នុងសេចក្តីសម្រេចចិត្តនានាដែលមានឥទ្ធិពលលើជីវិតរបស់ពួកគេ។

អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលជុំវិញពិភពលោកបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងលើការកាត់បន្ថយវិសមភាពក្នុងសង្គម និងការមិនទុកនរណាម្នាក់ឱ្យនៅក្រៅការអភិវឌ្ឍ ដើម្បីឈានទៅរកការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals)។ ប៉ុន្តែ ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងទាំងនេះ វិសមភាពនៅក្នុងសង្គមនៅតែមិនអាចលុបបំបាត់ចោលទាំងស្រុង ដែលធ្វើឱ្យក្រុមជនងាយរងគ្រោះមួយចំនួនមិនអាចទទួលបាននូវឱកាសនានាបានពេញលេញដូចជនដទៃ។ ខាងក្រោមនេះជាបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលក្រុមជនងាយរងគ្រោះ

នីមួយៗបាននិងកំពុងជួបប្រទះ រួមមាន៖

**ជនពិការ៖** បញ្ហាប្រឈមមួយចំនួនដែលជនពិការបាននិងកំពុងជួបប្រទះក្នុងជីវិតរស់នៅប្រចាំថ្ងៃគឺ កង្វះឧបករណ៍ជំនួយដែលធ្វើឱ្យពួកគាត់មានការលំបាកក្នុងការធ្វើបម្លាស់ទី, ការប្រាស្រ័យទាក់ទងជាមួយមនុស្សជុំវិញខ្លួន, ការសិក្សារៀនសូត្រ និងការបំពេញការងារនានា ហើយពួកគាត់ក៏រងគ្រោះដោយសារផ្នត់គំនិតសង្គម ដូចជា «ជនពិការមិនអាចបំពេញការងារបាន និងជាបន្ទុករបស់អ្នកដទៃ» ដែលផ្នត់គំនិតនេះអាចរារាំងជនពិការក្នុងការចូលរួមក្នុងកម្លាំងពលកម្ម។ លើសពីនេះទៀតយោងតាមគេហទំព័រ The World Bank កង្វះការទទួលបាននូវសេវាសាធារណៈពេញលេញក៏ជាបញ្ហាប្រឈមមួយដែលជនពិការមួយចំនួនកំពុងជួបប្រទះ ដោយសារតែពួកគាត់មានការលំបាកក្នុងការទទួលបានព័ត៌មានជាងជនដទៃ។

**កុមារ៖** កុមារងាយរងគ្រោះច្រើនជួបប្រទះនូវបញ្ហាប្រឈម ដូចជា កង្វះអាហារូបត្ថម្ភ, ការមិនសូវយកចិត្តទុកដាក់ពីគ្រួសារ, ការទទួលរងនូវអំពើហិង្សា, ការទទួលរងនូវការរំលោភបំពាន, ការជួញដូរពលកម្មដោយបង្ខំ, ការបោះបង់ចោលការសិក្សា និងការបង្ខំឱ្យរៀបការទាំងវ័យក្មេងជាដើម។ បញ្ហាប្រឈមទាំងនេះអាចបណ្ដាលឱ្យកុមារមានរបួសរាងកាយ, កើតជំងឺបាក់ទឹកចិត្ត, ងាយប្រឈមនឹងជំងឺ, អាចបណ្ដាលឱ្យគ្រោះថ្នាក់ដល់ជីវិត ព្រមទាំងបាត់បង់ឱកាសក្នុងការកសាងអនាគតដែលល្អប្រសើរ។

**ស្ត្រី៖** ស្ត្រីក៏ស្ថិតនៅក្នុងចំណោមក្រុមជនងាយរងគ្រោះ ដោយសារពួកគាត់ងាយប្រឈមនឹងបញ្ហាមួយចំនួន ដូចជា ការទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ ការទទួលខុសត្រូវលើកិច្ចការងារផ្ទះ ដែលធ្វើឱ្យពួកគាត់មិនអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងកម្លាំងពលកម្ម ការជួបប្រទះនូវវិសមភាពប្រាក់ខែ និងការរងគ្រោះដោយសារផ្នត់គំនិតយេនឌ័រ ដែលរារាំងពួកគាត់មិនឱ្យចូលរួមក្នុងសកម្មភាពនានានៅក្នុងសង្គម។ ជាក់ស្ដែង យោងតាមគេហទំព័រ UNDP ផ្នត់គំនិតយេនឌ័រដែលផ្ដល់អាទិភាពឱ្យបុរសទទួលបានការអប់រំខ្ពស់ជាងស្ត្រី និងការជំរុញឱ្យស្ត្រីឆាប់រៀបការនៅវ័យក្មេងជាងបុរស បានរារាំងស្ត្រីមួយចំនួនក្នុងការទទួលបានការអប់រំក្នុងកម្រិតឧត្តមសិក្សា។

**មនុស្សចាស់៖** មនុស្សវ័យចំណាស់តែងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជា វិបត្តិហិរញ្ញវត្ថុ, កង្វះប្រព័ន្ធជំនួយសង្គម, ការដាច់ឆ្ងាយពីសង្គម, ការថយចុះសមត្ថភាពរាងកាយ និងផ្លូវចិត្ត និងការពឹងផ្អែកលើគ្រួសារកាន់តែខ្លាំង។ មិនតែប៉ុណ្ណោះ យោងតាមគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី មនុស្សវ័យចំណាស់ដែលធ្លាប់បម្រើការងារក្នុងកម្លាំងពលកម្មក្រៅផ្លូវការកាន់តែងាយរងគ្រោះ ដោយសារការងារក្រៅផ្លូវការភាគច្រើនមិនបានរួមបញ្ចូលកម្មវិធីគាំពារសង្គម ដូចជា ប្រាក់សោធននិវត្តន៍នោះទេ។

**ជនជាតិភាគតិច៖** ជនជាតិភាគតិចនៃបណ្ដាប្រទេសនានាជុំវិញពិភពលោកបាននិងកំពុងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជា ការរើសអើង និងការមិនសូវមានអំណាចក្នុងសេចក្ដីសម្រេចចិត្តនានាដែលមានឥទ្ធិពលលើជីវិតរបស់ពួកគាត់ ដោយសារតែពួកគាត់ជាសំឡេងភាគតិច។ មិនតែប៉ុណ្ណោះ

យោងតាមគេហទំព័រ Right to Education ជនជាតិភាគតិចមួយចំនួនពុំទទួលបានការអប់រំដែលមានគុណភាព ដោយសារសាលារៀនដែលមានគុណភាពនៅតំបន់ដែលពួកគាត់រស់នៅមានចំនួនតិចនៅឡើយ ហើយអត្រាបោះបង់ចោលការសិក្សារបស់ជនជាតិភាគតិចក៏មានចំនួនច្រើន។ ការណ៍នេះបានធ្វើឱ្យជនជាតិភាគតិចមួយចំនួនពិបាកក្នុងការស្វែងរកការងារដែលមានចំណូលសមរម្យ ដែលធ្វើឱ្យពួកគាត់ត្រូវរស់នៅក្នុងស្ថានភាពក្រីក្រ។

## I. ទូទៅអំពីបរិយាបន្នសង្គមនៅកម្ពុជា

ប្រទេសកម្ពុជាបានផ្លាស់ប្តូរពីប្រទេសមានប្រាក់ចំណូលទាបមកជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ហើយកំណើនសេដ្ឋកិច្ចនេះបានជួយឱ្យកម្ពុជាក្លាយជាប្រទេសឈានមុខក្នុងការកាត់បន្ថយភាពក្រីក្រ។ ជាក់ស្តែង យោងតាមគេហទំព័រ The World Bank ចាប់តាំងពីឆ្នាំ ២០០៩ ដល់ឆ្នាំ២០១៩ អត្រាភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះជាមធ្យមប្រមាណ **១,៦ភាគរយ** ក្នុងមួយឆ្នាំ។ ប៉ុន្តែ ទន្ទឹមនឹងការកាត់បន្ថយភាពក្រីក្រនេះ ក្រុមជនងាយរងគ្រោះនៅកម្ពុជានៅតែជួបប្រទះនូវឧបសគ្គដែលរារាំងពួកគាត់ក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច សង្គមបានពេញលេញ។ ជាក់ស្តែង យោងតាម**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** គិតត្រឹមឆ្នាំ ២០១៩ ជនពិការនៅកម្ពុជាមានចំនួនប្រមាណ **៣១ម៉ឺននាក់** ហើយការរើសអើងជនពិការ និងកង្វះការលើកទឹកចិត្តពីគ្រួសារ និងមនុស្សនៅក្នុងសហគមន៍ ព្រមទាំងកង្វះហេដ្ឋារចនាសម្ព័ន្ធដែលអាចឆ្លើយតបតាមតម្រូវការរបស់ជនពិការពិសេសជនពិការនៅតាមទីជនបទនៅកម្ពុជា បានក្លាយជាឧបសគ្គរារាំងជនពិការទាំងនេះក្នុងការចូលរួមក្នុងសកម្មភាពនានានៅក្នុងសង្គម។ លើសពីនេះទៀត ការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពប្រជាពលរដ្ឋកម្ពុជាហើយក្រុមជនងាយរងគ្រោះគឺជាអ្នកដែលរងគ្រោះខ្លាំងបំផុតពីវិបត្តិនេះ។ ជាក់ស្តែង យោងតាមអង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (FAO) វិបត្តិជំងឺកូវីដ-១៩ បានធ្វើឱ្យក្រុមជនងាយរងគ្រោះ រួមមាន ស្ត្រី កុមារ ជនជាតិដើមភាគតិច និងពលករចំណាកស្រុករងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរ ដោយសារតែភាពអត់ការងារធ្វើ និងកង្វះការងារសម្រាប់អ្នកប្រកបរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ឆ្លើយតបនឹងបញ្ហានេះ បន្ថែមលើគោលនយោបាយ និងផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការសំខាន់ៗជាបន្តបន្ទាប់ ដើម្បីគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ លើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ក្នុងនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ហើយបើគិតចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២នេះ បានចំណាយថវិការដ្ឋអស់ប្រមាណជាង ៥៩២លានដុល្លារអាមេរិក។

## ១. បច្ចេកវិទ្យា និងបរិយាបន្នសង្គមនៅកម្ពុជា

បច្ចេកវិទ្យាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា មិនថា ការសិក្សារៀនសូត្រ ការបំពេញការងារ ការធ្វើអាជីវកម្ម ការប្រាស្រ័យទាក់ទង និងការកម្សាន្តនោះទេ។ ទន្ទឹមនឹងនេះ បច្ចេកវិទ្យាជាច្រើនត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់ការរស់នៅរបស់ក្រុមជនងាយរងគ្រោះនៅជុំវិញពិភពលោក រួមទាំងកម្ពុជាផងដែរ ដើម្បីអាចឱ្យពួកគាត់ចូលរួមនៅក្នុងសកម្មភាពនានាបានដូចពលរដ្ឋដទៃ។ ខាងក្រោមនេះ ជាបច្ចេកវិទ្យាសំខាន់ៗមួយចំនួនដែលមានសក្ដានុពលសម្រាប់ក្រុមជនងាយរងគ្រោះនៅកម្ពុជា រួមមាន៖

**បច្ចេកវិទ្យាជំនួយ៖** បច្ចុប្បន្ននេះ ជនពិការភ្នែកនៅកម្ពុជាអាចទទួលបានផលប្រយោជន៍ជាច្រើនពីបច្ចេកវិទ្យាជំនួយ ដូចជា កម្មវិធីអានអេក្រង់ (Screen Reader) ដែលអាចជួយអានអក្សរនៅលើអេក្រង់ទូរស័ព្ទ កុំព្យូទ័រ និងថេប្លេត, កម្មវិធី Voice Typing ដែលអាចជួយវាយឬកែសម្រួលអត្ថបទ តាមការនិយាយ, រទេះរុញ និងឧបករណ៍ជំនួយការស្ដាប់ជាដើម។ ជាក់ស្ដែង យោងតាមបទយកការណ៍ស្ដីពី «ជនពិការភ្នែកនាពេលបច្ចុប្បន្ន ខុសពីជនពិការភ្នែកកាលពីអតីតកាល» របស់**ក្រសួងព័ត៌មាន** បច្ចេកវិទ្យាជំនួយទាំងនេះបានជួយឱ្យជនពិការអាចបំពេញការងារនានាបានងាយស្រួលជាងមុន មិនថា ការសិក្សារៀនសូត្រ ការប្រកបការងារ ការធ្វើដំណើរ ការប្រាស្រ័យទាក់ទងនឹងមនុស្សជុំវិញខ្លួន និងការទទួលបានព័ត៌មាន ហើយសូម្បីតែជនពិការភ្នែកក៏អាចប្រើប្រាស់បច្ចេកវិទ្យាជំនួយ ដើម្បីអាចប្រើប្រាស់ផែនទីតាមទូរស័ព្ទបានដែរ។



**បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT)៖** យោងតាមរបាយការណ៍ស្តីពី «តម្រូវការ និងបញ្ហាប្រឈមរបស់មនុស្សចាស់» នៃវិទ្យាស្ថានជាតិសង្គមកិច្ច នៅឆ្នាំ ២០១៩ មនុស្សវ័យចំណាស់នៅកម្ពុជា ពិសេសអ្នកដែលមានកូនៗធ្វើចំណាកស្រុកទៅធ្វើការនៅបរទេស និងអ្នកដែលមានជំងឺរ៉ាំរ៉ៃ តែងរស់នៅដាច់ឆ្ងាយពីសង្គម និងមានអារម្មណ៍ឯកា។ ក្នុងន័យនេះ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដូចជា ទូរស័ព្ទដៃវៃឆ្លាត, វេទិកាអនឡាញ, អ៊ីម៉ែល, កម្មវិធីជជែកផ្ទាល់ (Live Chat) និងកម្មវិធីខលជាវីដេអូជាដើម បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាទំនាក់ទំនងរវាងមនុស្សវ័យចំណាស់ជាមួយក្រុមគ្រួសារ មិត្តភក្តិ និងមនុស្សក្នុងសហគមន៍។



**ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖** ស្ត្រីនៅកម្ពុជាមួយចំនួនមិនបានចូលរួមនៅក្នុងកម្លាំងពលកម្មដូចបុរស ដោយសារតែពួកគាត់ត្រូវទទួលខុសត្រូវលើការងារ ដូចជា មើលថែផ្ទះ មើលថែកូន និងមនុស្សវ័យចំណាស់នៅក្នុងគ្រួសារជាដើម។ ប៉ុន្តែ បច្ចុប្បន្ននេះ ស្ត្រីដែលមិនអាចចូលរួមក្នុងកម្លាំងពលកម្មពេញម៉ោងអាចរកប្រាក់ចំណូលបានតាមរយៈពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រោះថាពួកគាត់អាចលក់នូវផលិតផល ឬសេវាកម្មនានាបានក្នុងពេលវេលាដែលសមស្រប។ ជាក់ស្តែង ដោយមើលឃើញថាស្ត្រីនៅតាមទីជនបទមិនមានជម្រើសច្រើនក្រៅពីធ្វើកិច្ចការងារផ្ទះ និងមើលថែគ្រួសារលោកស្រី វត្ថា វិច្ឆិកា ដែលជាស្ថាបនិក**ក្រុមហ៊ុនដៃខ្មែរ** បានផ្តល់ឱកាសឱ្យស្ត្រីនៅតាមទីជនបទអាចរកប្រាក់ចំណូលបាន តាមរយៈការផលិតនូវផលិតផលធម្មជាតិ រួចដាក់លក់នៅលើថ្នាល ដូចជា គេហទំព័រ និងបណ្តាញ

សង្គម Facebook, Instagram និងTikTok របស់ដៃខ្មែរ។ យោងតាមគេហទំព័រសមាគមសហគ្រិនស្ត្រីកម្ពុជា បើទោះបីជាមានការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ  ផលិតផលដៃខ្មែរនៅតែអាចរកចំណូលបានកាន់តែច្រើន ដោយសារការទាញយកសក្តានុពលពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចជួយលើកកម្ពស់គុណភាពជីវិតស្ត្រីនៅតាមទីជនបទនៅក្នុងប្រទេសកម្ពុជាជាច្រើននាក់។



**កម្មវិធីទូរស័ព្ទ៖** យោងតាមការសិក្សាស្រាវជ្រាវរបស់លោក ពៅ សុគន្ធរឹទ្ធិ ស្តីពី «**កត្តាជះឥទ្ធិពលលើការបោះបង់ចោលការសិក្សានៅកម្រិតអនុវិទ្យាល័យនៅតាមទីជនបទនៃប្រទេសកម្ពុជា**» នៅឆ្នាំ ២០១៩ កុមារនៅតាមទីជនបទមួយចំនួនត្រូវជួយកិច្ចការងារស្រែចំការរបស់ឪពុកម្តាយ ដែលធ្វើឱ្យពួកគាត់អវត្តមានពីថ្នាក់រៀនជាច្រើនដង។ ករណីនេះ អាចធ្វើឱ្យពួកគាត់ចាប់ផ្តើមមានអារម្មណ៍ខ្លាចសាលារៀន និងរៀនមិនទាន់។ ក្នុងន័យនេះ បច្ចេកវិទ្យាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការអប់រំប្រកបដោយបរិយាបន្ន ដោយបានអនុញ្ញាតឱ្យសិស្សគ្រប់រូបអាចធ្វើការសិក្សាបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ ជាឧទាហរណ៍ សិស្សានុសិស្សអាចប្រើប្រាស់កម្មវិធី «MoEYS E-Learning» ដើម្បីធ្វើស្វ័យសិក្សាបន្ថែមដោយខ្លួនឯង ដូចជា រំលឹកមេរៀន ឬរៀនត្រៀមសម្រាប់មេរៀនណាមួយដែលចាំបាច់ នៅគ្រប់កម្រិតសិក្សានៃការអប់រំចំណេះទូទៅ ទៅតាមពេលវេលា និងទីកន្លែងដែលសមប្រកប។




## ២. កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធក្នុងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីលើកកម្ពស់បរិយាបន្នសង្គមនៅកម្ពុជា

បច្ចុប្បន្ននេះ បើទោះបីជាវិសមភាពនៅតែកើតមាននៅក្នុងសង្គមកម្ពុជា យើងនៅតែអាចមើលឃើញពីវឌ្ឍនភាពនៃការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច សង្គមរបស់ក្រុមជនងាយរងគ្រោះកាន់តែច្រើនឡើង។ នេះដោយសារតែការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងគ្រប់ភាគីពាក់ព័ន្ធក្នុងការទាញយកសក្តានុពលពីបច្ចេកវិទ្យា ដើម្បីជួយសម្រួលដល់ពលរដ្ឋងាយរងគ្រោះឱ្យកាន់តែមានភាពងាយស្រួលក្នុងការចូលរួមក្នុងសកម្មភាពនានាក្នុងសង្គម ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈ សំដៅលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋគ្រប់រូប រួមទាំងក្រុមជនងាយរងគ្រោះ។ ខាងក្រោមនេះជាសកម្មភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល និងគ្រប់ភាគីពាក់ព័ន្ធក្នុងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីលើកកម្ពស់បរិយាបន្នសង្គមនៅកម្ពុជា ដូចជា៖

### រាជរដ្ឋាភិបាល៖

**គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ឆ្នាំ២០១៧ - ឆ្នាំ២០៣០៖** បញ្ហាប្រឈមមួយដែលមនុស្សចាស់បាននិងកំពុងជួបប្រទះគឺកង្វះការប្រាស្រ័យទាក់ទងជាមួយសមាជិកគ្រួសារ និងមនុស្សក្នុងសហគមន៍ ដែលធ្វើឱ្យពួកគាត់មានអារម្មណ៍ថាឯកា។ ហេតុនេះហើយ នៅក្នុង «**គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ឆ្នាំ២០១៧ - ឆ្នាំ២០៣០**» រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្រ្តក្នុងការរៀបចំការបណ្តុះបណ្តាល និងការគាំទ្រដល់មនុស្សចាស់លើបញ្ហាប្រើប្រាស់មធ្យោបាយប្រាស្រ័យទាក់ទងគ្នា ដូចជា ទូរស័ព្ទដៃ និងប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីឱ្យពួកគាត់អាចរក្សាទំនាក់ទំនងជាមួយកូនចៅ មនុស្សពេញវ័យ និងសាច់ញាតិក្មេងៗដទៃទៀតរបស់ពួកគាត់។

**▶ ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០៖** ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើត «**ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០**» ដើម្បីផ្តល់នូវសេវាអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន សម្រាប់កុមារតូច ព្រមទាំងសិស្សបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេស ការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព និងផលិតភាព ស្របតាមយុគសម័យបច្ចេកវិទ្យា។ ហេតុនេះហើយ ក្រសួងនឹងផ្តល់ឱ្យសាលារៀននូវកុំព្យូទ័រ អ៊ីនធឺណិត បណ្ណាល័យ និងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ព្រមទាំងបង្កើតនូវវគ្គសិក្សាចំហតាមប្រព័ន្ធអ៊ីនធឺណិត ដែលអាចជាជំនួយដល់ការសិក្សារបស់សិស្សគ្រប់រូបដោយមិនប្រកាន់ពីភេទ ជនជាតិ ភាសាដើមកំណើត កាយសម្បទា និងស្ថានភាពងាយរងគ្រោះ។

**▶ កម្មវិធីអត្តសញ្ញាណកម្មពិការភាព៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** កំពុងអភិវឌ្ឍន៍កម្មវិធីអត្តសញ្ញាណកម្មពិការភាព ដើម្បីផ្តល់ភាពងាយស្រួលដល់ជនពិការក្នុងការចុះឈ្មោះសុំប័ណ្ណសំគាល់ពិការភាព។ ជាមួយនឹងកម្មវិធីទូរស័ព្ទនេះ រាជរដ្ឋាភិបាលនឹងមានភាពងាយស្រួលក្នុងការគ្រប់គ្រងទិន្នន័យជនមានពិការភាពទូទាំងប្រទេស ព្រមទាំងអាចផ្តល់សេវាសាធារណៈ និងអត្ថប្រយោជន៍ ដូចជាសេវាគាំពារសង្គម អាទិភាពការងារក្នុងស្ថាប័នរដ្ឋ និងឯកជន សេវាសុខាភិបាលនៅគ្រប់មូលដ្ឋានសុខាភិបាលសាធារណៈ និងមណ្ឌលស្តារកាយសម្បទា ព្រមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការបានកាន់តែប្រសើរ។

### ▶ ភាគីពាក់ព័ន្ធ៖

**▶ បច្ចេកវិទ្យាជំនួយសម្រាប់កសិករពិការ៖** ប្រជាជននៅតាមទីជនបទនៅប្រទេសកម្ពុជាភាគច្រើនពឹងផ្អែកលើការធ្វើស្រែចំការ ដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ដោយសារតែគ្រាប់មីនសល់ពីសង្គ្រាមរ៉ាំរ៉ៃ គ្រោះថ្នាក់ចរាចរណ៍ និងជំងឺកាចសាហាវនានាបានធ្វើឱ្យប្រជាជនមួយចំនួនក្លាយជាជនពិការ។ ហេតុនេះហើយ ដើម្បីជួយឱ្យជនពិការអាចបន្តការធ្វើស្រែចំការបាន ក្រុមហ៊ុន Agrilab បានសហការជាមួយអង្គការ Light for the World និងអង្គការ Engineers Without Borders ដើម្បីបង្កើតបច្ចេកវិទ្យាជំនួយ ដូចជា ម៉ាស៊ីនដែលប្រើសម្រាប់សាបព្រួស និងកប់គ្រាប់ពូជទៅក្នុងដី និងរទេះប្រមូលផលដែលអាចប្រើជំនួសការប្រមូលផលដំណាំដោយដៃ។ បច្ចុប្បន្ន ម៉ាស៊ីនទាំងនេះមានផ្គត់ផ្គង់នៅក្នុងខេត្តពោធិ៍សាត់។

**▶ កម្មវិធីកត់ត្រារៀល៖** ស្ត្រីមួយចំនួននៅប្រទេសកម្ពុជាមិនបានទទួលការអប់រំខ្ពស់ ដោយសារតែពួកគាត់ត្រូវរៀបការនៅវ័យក្មេងពេក និងរងគ្រោះដោយសារផ្នត់គំនិតស្ត្រីវិលចង្ក្រានមិនជុំ ដែលធ្វើឱ្យពួកគាត់មិនមានចំណេះដឹងច្រើនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៃអាជីវកម្មរបស់ពួកគាត់។ ហេតុនេះហើយ She Investments Cambodia បានបង្កើតកម្មវិធីទូរស័ព្ទកត់ត្រារៀល ដើម្បីអនុញ្ញាតឱ្យស្ត្រីដែលមានចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅមានកម្រិត អាចរក្សាកំណត់ត្រា និងគ្រប់គ្រងហិរញ្ញវត្ថុបានងាយស្រួល។ ការណ៍នេះអាចជួយឱ្យអាជីវកម្មរបស់ពួកគាត់មានការរីកចម្រើន និងអាចឈានទៅរកការពង្រីកអាជីវកម្មបាន។

**ប្រព័ន្ធអប់រំតាមបែបឌីជីថល៖** នៅឆ្នាំ២០២០ **នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃក្រសួងអប់រំ យុវជន និងកីឡា** បានចុះកិច្ចព្រមព្រៀងជាមួយអង្គការ ChildFund Cambodia ដើម្បីបំពាក់ប្រព័ន្ធអប់រំតាមបែបឌីជីថលដល់សាលារៀននៅតាមទីជនបទ។ គម្រោងនេះនឹងផ្តល់ឱ្យសាលារៀននូវប្រព័ន្ធមាតិកាឌីជីថល (Content Server) ដែលផ្ទុកទៅដោយឯកសារមេរៀន និងធនធានអប់រំជាច្រើនពីគេហទំព័រនានា ជាពិសេសគេហទំព័រគ្រូ www.krou.moeys.gov.kh ដែលអនុញ្ញាតឱ្យសិស្សអាចទាញយកមេរៀនមករៀនសូត្រ ដោយមិនចាំបាច់មានប្រព័ន្ធអ៊ីនធឺណិតឡើយ។ ដូច្នេះកុមារដែលមិនមានលទ្ធភាពក្នុងការប្រើប្រាស់សេវាអ៊ីនធឺណិតក៏អាចទាញយកផលប្រយោជន៍ពីប្រព័ន្ធឌីជីថលនេះដែរ។ ប្រព័ន្ធអប់រំឌីជីថលនេះនឹងចូលរួមចំណែកក្នុងការកាត់បន្ថយអត្រាបោះបង់ចោលការសិក្សារបស់សិស្សនៅអំឡុងពេលវិបត្តិនៃជំងឺកូវីដ-១៩ ព្រមទាំងផ្តល់ឱកាសឱ្យសិស្សអាចសម្របខ្លួននឹងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលផងដែរ។

## II. សន្និដ្ឋាន

ជារួម ក្រុមជនងាយរងគ្រោះនៃបណ្តាប្រទេសនានាជុំវិញពិភពលោក រួមទាំងកម្ពុជា បាននិងកំពុងជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដែលរារាំងពួកគាត់ក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច សង្គម បានពេញលេញដូចជនដទៃ។ បញ្ហារបស់ក្រុមជនងាយរងគ្រោះនេះក៏បានបង្កជាផលប៉ះពាល់អវិជ្ជមានដល់កំណើនសេដ្ឋកិច្ចជាតិ ដោយសារការបាត់បង់សក្តានុពលធនធានមនុស្ស។ ក្នុងន័យនេះ ដើម្បីចូលរួមចំណែកដល់ការលើកកម្ពស់បរិយាបន្នសង្គម បច្ចេកវិទ្យាជាច្រើនត្រូវបានបង្កើតឡើងសម្រាប់ជួយសម្រួលដល់ក្រុមជនងាយរងគ្រោះក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច សង្គម ព្រមទាំងបង្កើនឱកាសដល់ពួកគាត់ក្នុងការទទួលបាននូវធនធាន និងសេវានានា។ ដូច្នេះ រដ្ឋាភិបាល និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវបន្តរួមគ្នាជាធ្លុងមួយក្នុងការបង្កើនការផ្តល់សេវាកម្មឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដែលអាចឆ្លើយតបតាមតម្រូវការរបស់ក្រុមជនងាយរងគ្រោះ ព្រមទាំងបន្តចែករំលែក និងផ្តល់ការបណ្តុះបណ្តាលដល់ក្រុមជនងាយរងគ្រោះពីការប្រើប្រាស់បច្ចេកវិទ្យាទាំងនោះ ដើម្បីឱ្យពួកគាត់មានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទាញយកសក្តានុពលពីបច្ចេកវិទ្យា៕

## ឯកសារយោង


- *The importance of social inclusion*, ចូលអានថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២២, https://www.sacredheartmission.org/news/the-importance-of-social-inclusion/
- *UNICEF កិច្ចការពារសម្រាប់កុមារគ្រប់រូប*, ចេញផ្សាយ ឆ្នាំ២០១៨, ចូលអានថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២២, https://www.unicef.org/cambodia/km/%E1%9E%80%E1%9E%B7%E1%9E%85%E1%9F%92%E1%9E%85%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%96%E1%9E%B6%E1%9E%9A%E1%9E%80%E1%9E%BB%E1%9E%98%E1%9E%B6%E1%9E%9A
- *ឥរិយាបទទំនាក់ទំនង និងឥរិយាបទយេនឌ័រ ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា*, ចេញផ្សាយឆ្នាំ២០១៤, ចូលអានថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២២, https://www1.undp.org/content/dam/cambodia/docs/DemoGov/NearyRattanak4/Neary%20Rattanak%204%20-%20PB%20Gender%20Relations%20and%20Attitudes_Kh.pdf
- *SOCIAL PROTECTION FOR INFORMAL WORKERS IN ASIA*, ចេញផ្សាយ ឆ្នាំ២០១៦, ចូលអានថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២២, https://www.adb.org/sites/default/files/publication/203891/sp-informalworkers-asia.pdf
- *Disability Inclusion*, ចេញផ្សាយថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២, ចូលអានថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២២, https://www.worldbank.org/en/topic/disability#1
- *Minorities and Indigenous Peoples*, ចូលអានថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២២, https://www.right-to-education.org/issue-page/marginalised-groups/minorities-and-indigenous-peoples
- *Country Overview Cambodia*, ចេញផ្សាយថ្ងៃ២៩ ខែមីនា ឆ្នាំ២០២២, ចូលអានថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២២, https://www.worldbank.org/km/country/cambodia/overview#1
- *CDPO announces plan to compile data on disabled*, ចេញផ្សាយថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៩, ចូលអានថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២២, https://www.phnompenhpost.com/national/cdpo-announces-plan-compile-data-disabled
- *ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមនៃជំងឺកូវីដ-១៩ មកលើប្រទេសកម្ពុជា*, ចេញផ្សាយថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២០, ចូលអានថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២២, https://opendevelopmentcambodia.net/km/profiles/socio-economic-impact-of-covid-19-on-cambodia/#ref-124694-14
- *បទយកការណ៍៖ ជនពិការភ្នែកនាពេលបច្ចុប្បន្ន ខុសពីជនពិការភ្នែកកាលពីអតីតកាល*, ចេញផ្សាយ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៩, ចូលអានថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២២, https://www.information.gov.kh/articles/22345
- *How Small Businesses Have Coped with the Impact of COVID-19*, ចូលអានថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២២, http://www.cweacambodia.org/en/news-update/227/how-small-businesses-have-coped-with-the-impact-of-covid-19
- *Factors Influencing Dropout at Lower Secondary Schools in Rural Cambodia*, ចេញផ្សាយ ខែមីនា

ឆ្នាំ ២០១៩, ចូលអានថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២២, https://www.researchgate.net/publication/333338809_Factors_Influencing_Dropout_at_Lower_Secondary_Schools_in_Rural_Cambodia

- កម្មវិធីស្វ័យសិក្សា «MoEYS E-Learning» គិតគូរជាអាទិភាពក្នុងភាពជាខ្មែរ សម្រាប់អនាគតកូនខ្មែរ, ចេញផ្សាយថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០២១, ចូលអានថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២២, https://www.uyfc.org/news/moeys-e-learning-2/
- គោលនគោបាយជាតិស្តីពីមនុស្សវ័យចាស់២០១៧-២០៣០, ចេញផ្សាយថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧, ចូលអានថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២២, http://mosvy.gov.kh/wp-content/uploads/2021/05/%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99%E1%9E%87%E1%9E%B6%E1%9E%8F%E1%9E%B7%E1%9E%9F%E1%9F%92%E1%9E%8F%E1%9E%B8%E1%9E%96%E1%9E%B8%E1%9E%98%E1%9E%93%E1%9E%BB%E1%9E%9F%E1%9F%92%E1%9E%9F%E1%9E%9C%E1%9F%90%E1%9E%99%E1%9E%85%E1%9E%B6%E1%9E%9F%E1%9F%8B_%E1%9F%A2%E1%9F%A0%E1%9F%A1%E1%9F%A7_%E1%9F%A2%E1%9F%A0%E1%9F%A3%E1%9F%A0.pdf
- ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជាឆ្នាំ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤, ចេញផ្សាយ ខែ កុម្ភៈ ឆ្នាំ ២០១៩, ចូលអានថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២២, http://www.moeys.gov.kh/index.php/kh/planning/2901.html#.YmoTLtpBw2x
- Disabled people to be digitally registered, ចេញផ្សាយថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២១, ចូលអានថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២២, https://www.khmertimeskh.com/50807880/disabled-people-to-be-digitally-registered/
- In rural Cambodia, co-designed technology gives better access to livelihoods, ចេញផ្សាយថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០២០, ចូលអានថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២២, https://ewb.org.au/blog/2020/12/03/in-rural-cambodia-co-designed-technology-gives-better-access-to-livelihoods/
- Business bosses share insights on empowering Asia´s rural women entrepreneurs, ចេញផ្សាយថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២១, ចូលអានថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២២, https://www.khmertimeskh.com/501015936/business-bosses-share-insights-on-empowering-asias-rural-women-entrepreneurs
- ក្រសួងអប់រំ និងអង្គការ ChildFund សហការគ្នា លើកកម្ពស់ការអប់រំឌីជីថល សម្រាប់បឋមសិក្សានៅតំបន់ជនបទ, ចេញផ្សាយថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០, ចូលអានថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២២, http://www.moeys.gov.kh/index.php/kh/dgaf/3758.html#.Ymtl3e1ByyJ
- សេចក្តីជូនដំណឹង របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីលទ្ធផលនៃការអនុវត្តការបើកសាច់ប្រាក់ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, ចេញផ្សាយថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២២, ចូលអានថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២២

---

www.cambodia4point0.org

កម្ពុជា ៤.0 - Cambodia 4.0

cambodia_4.0

កម្ពុជា ៤.0 Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

Cambodia 4.0 Center